ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការក្រុងព្រះសីហនុ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១២៨ចុះថ្ងៃទី ០៨
ខែ ឧសភា ឆ្នាំ ២០០១
សាលក្រម
លេខ ១០០ ចុះថ្ងៃទី ១៧
ខែ វិច្ឆិកា ឆ្នាំ ២០០៤

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការក្រុងព្រះសីហនុ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]ខា

សាលក្រមនេះចូលស្ថាពរហើយ
ក្រុងព្រះសីហនុ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥
ក្រឡាបញ្ជី [redacted]

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២៨ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០១ ដែលមានជនជាប់ចោទឈ្មោះ :

-ស ស ហៅ គ ម ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិពោធិ ឃុំបន្ទាយមាស ស្រុកបន្ទាយមាស ខេត្តកំពត ទីលំនៅមុនពេលចាប់ខ្លួននៅភូមិស៊ីរុងកណ្តាល សង្កាត់ស៊ីរុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ របររកស៊ីធ្វើស្រែ ឪពុកឈ្មោះ ម ស (រ) ម្តាយឈ្មោះ ឌ ស (រ) ប្រពន្ធឈ្មោះ ឌ ម មានកូន ០២នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៤ ។

ជាប់ចោទពីបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិអូរត្រជាក់ចិត្ត សង្កាត់ស៊ីរុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ អ ផល ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើចំការ មានទីលំនៅភូមិអូរត្រជាក់ចិត្ត សង្កាត់ស៊ីរុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាជនរងគ្រោះ ។

-ឈ្មោះ គ ព ភេទស្រី អាយុ ៦៤ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើចំការ ទីលំនៅសព្វថ្ងៃ ភូមិអូរត្រជាក់ចិត្ត សង្កាត់ស៊ីរុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៦៤ ដសព ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០១ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៦២៩ ត.ព ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៦៣០ គ.ព ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ដំណើររឿងហេតុមានដូចតទៅ :

-កាលពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ ឈ្មោះ **ស ស** ហៅ **គ ម** បានទៅផ្ទះ **អ ផល** ក្នុងគោលបំណងទៅជួបឈ្មោះ **ម** ត្រូវជាបងថ្លៃ ឱ្យឈ្មោះ **អ ផល** ដើម្បីយកប្រាក់ទៅឱ្យសំរាប់កាប់ចំការ តែទៅមិនជួបឈ្មោះ **ផល** ក៏ចេញទៅចំការមើលឡដុតធ្យូង ឈ្មោះ **ស ស** ក៏ទៅតាមក្រោយដែរ ពេលដល់ចំការឈ្មោះ **ស ស** ក៏សុំសេចក្តីស្នេហាពីនាងឈ្មោះ **អ ផល** មិនតបតអីទេ ឈ្មោះ **ស ស** ក៏ចាប់នាង **ផល** ផ្តួលលើដី រួចក៏ទ្រោបពីលើនាង **ផល** ក៏ចេញទឹកកាមទៅបន្តិចក្រោយមកឈ្មោះ **ស ស** សុំសេចក្តីស្នេហាពីឈ្មោះ **ផល** តែឈ្មោះ **ផល** ថា ក្មួយខ្លួនមកទាន់ឥឡូវហើយ ក៏ឃើញក្មួយមកមែន ក៏បាននាំគ្នាមកផ្ទះវិញ ក្រោយមកស្រាប់តែឈ្មោះ **គ ព** ដែលជាម្តាយឈ្មោះ **ផល** បានប្តឹងទៅសង្កាត់ចោទប្រកាន់ថា ឈ្មោះ **ស ស** បានរំលោភកូនគាត់ ។ ឈ្មោះ **ស ស** ភ័យក៏រត់គេចខ្លួន រហូតដល់ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ សមត្ថកិច្ចចាប់ខ្លួនបាន ។

## នារពលសទនាការ

-ឈ្មោះ **ស ស** ហៅ **គ ម** ជាជនជាប់ចោទបានឆ្លើយថា មុនពេលកើតហេតុឈ្មោះ **ម** ត្រូវជាបងថ្លៃរបស់ឈ្មោះ **អ ផល** បានប្រាប់ខ្លួនថា ឱ្យខ្លួនយកប្អូនថ្លៃគាត់ឈ្មោះ **ផល** ធ្វើជាប្រពន្ធតទៅអនាគតទៅ ព្រោះប្រពន្ធមុនខ្លួនបានធ្វើការលែងលះគ្នារួចហើយ ទើបឈ្មោះ **ម** គាត់ហ៊ាននិយាយថា ឱ្យប្អូនថ្លៃគាត់យ៉ាងដូច្នេះ ។ ក្រោយមកខ្លួនក៏បាននិយាយលេងជាមួយ **ផល** ហើយក៏បានកៀកគ្នា មើលទៅគេមានចិត្តស្រឡាញ់មកលើខ្លួនដែរ ខ្លួនក៏បានសំរាកនៅលើផ្ទះរបស់ឈ្មោះ **ម** នោះទៅ ប៉ុន្តែមិនបានរួមរ័ក្សគ្នាទេ រំលងបាន ១០ថ្ងៃ ក្រោយមកឈ្មោះ **ម** បានប្រាប់ខ្លួន ថា គេចែកដីចំការឱ្យខ្លួន តែឱ្យខ្លួនត្រៀមរកលុយឱ្យគាត់បានចំនួន ១០០.០០០៛០០ ( ដប់ម៉ឺនរៀល ) និង អង្ករចំនួន ០១បាវថ្លៃឈ្នួលកាប់ភ្ការព្រៃឱ្យរហូតដល់ថ្ងៃ ១៥ ខែ មីនា ឆ្នាំ ២០០១ ខ្លួនក៏បានយកលុយទៅឱ្យឈ្មោះ **ម** នៅភូមិអូរត្រជាក់ចិត្ត ពេលទៅដល់ផ្ទះមិនបានជួបឈ្មោះ **ម** ទេ ក៏បានជួបឈ្មោះ **ផល** ភេទស្រី នៅផ្ទះ ខ្លួនក៏បានសួររកឈ្មោះ **ម** ឈ្មោះ **ផល** ប្រាប់ថា ឈ្មោះ **ម** អត់នៅទេ ឈ្មោះ **ផល** គេថា ខ្លួនគេបន្តិចទៀតគេនឹងទៅចំការដែរ សួរខ្លួនថាទៅមើលចំការរបស់ខ្លួនដែលបង **ម** ឱ្យខ្លួននោះដែរឬអត់ ខ្លួនថា ព្រមទៅមើល ឈ្មោះ **ផល** ក៏ចេញទៅចំការ ឯខ្លួនក៏ដើរតាមក្រោយរហូតដល់ចំការ ពេលដល់ចំការខ្លួនឈរនៅខាងលិច ឯ **ផល** ឈរនៅខាងកើត ខ្លួនក៏សុំសេចក្តីស្នេហាពីនាង ខ្លួនសួរជាច្រើនដង ឈ្មោះ **ផល** គេនៅស្ងៀម ខ្លួនគិតថា គេមិនជំទាស់ និង សេចក្តីស្នេហានេះដែរ ព្រោះខ្លួនយល់ថា កន្លងមកគេមានចិត្តស្រឡាញ់មកលើខ្លួនខ្លាំងណាស់ដែរ ដោយគិតថា មានការនៅស្ងៀមនេះ ប្រហែលជាយល់ព្រមឱ្យសេចក្តីស្នេហាហើយខ្លួនក៏យកដៃម្ខាងទៅកាន់ចង្កេះនាង ឃើញគេមិនរើបំរះអ្វីទាំងអស់ ហើយដៃម្ខាងទៀតខ្លួនដោះខ្សែក្រវ៉ាត់ខ្លួនឯងដោះរួចហើយ ខ្លួនក៏ត្រកងបីនាងឱ្យដេកលើដី ខ្លួនក៏បានទ្រោបពីលើនាង **ផល** មិនបានស្រាតខោខ្លួន និង ស្រាតខោនាង **ផល** ផង ស្រាប់តែខ្លួនក៏បានចេញទឹកកាមប្រឡាក់ខោខ្លីរបស់ខ្លួនអស់ ខ្លួនក៏ងើបឡើងពីលើខ្លួន **ផល** ក៏នាំគ្នាអង្គុយនៅក្បែរមាត់ឡដុតធ្យូង ខ្លួនក៏យកដៃដាក់លើស្មានាង តែនាងមិនរុញដៃខ្លួនចេញទេ បន្តិចក្រោយមកខ្លួនក៏សុំសេចក្តីស្នេហាពីនាងម្តងទៀត ពេលនោះឈ្មោះ **ផល** បានប្រាប់ខ្លួនថា ក្មួយរបស់គាត់មកពីមើលមងឥឡូវហ្នឹង ហើយខ្លួនក៏បាននិយាយពីរបីម៉ាត់ទៀត ស្រាប់តែឃើញក្មួយប្រុស អាយុ ១៧ឆ្នាំរបស់ **ផល** មកដល់ល្មម ខ្លួនក៏ងើបដើរចេញពី **ផល** ហើយក៏នាំគ្នាដើរមកផ្ទះ **ផល** ក៏ដើរតាមក្រោយខ្លួនរហូតមក ខ្លួនក៏បានឱ្យលុយទៅ **ផល** ចំនួន ២០ដុល្លា និង លុយ

ខ្មែរ ២០.០០០រ០០ សំរាប់ថ្លៃកាប់ឆ្ការព្រៃចំការឱ្យខ្លួន ដែលឈ្មោះ ម បានឱ្យដីមកខ្លួនទំហំ ១០០ម×៥០០ម ចំពោះបញ្ហានេះខ្លួនមិនបានរំលោភសេពសន្ថវៈ ដូចជាការចោទប្រកាន់ទេ គឺខ្លួនគ្រាន់តែបានថើប និង ស្ទាបដោះតែមែន និងមិនបានស្រាតខោរបស់ ៥ល នោះឡើយ ហើយខ្លួននៅតែស្រឡាញ់នាងដដែល ប៉ុន្តែឥឡូវនេះ នាង ៥ល គេបានរៀបការជាមួយប្តីរួចហើយ ថែមទាំងមានកូន ០១ទៀតផង ។ ខ្លួនមិនដឹងថា យ៉ាងម៉េចទេបានជាគាត់ប្តឹងខ្លួន ហើយចោទថា ខ្លួនបានរំលោភយ៉ាងដូច្នេះ ម្តាយខ្លួនក៏អង្វរម្តាយខាង ៥ល ដែរ ហើយគាត់មិនថាអ្វីដែរ ខ្លួនមានការភិតភ័យខ្លួនក៏គេចខ្លួន ម្តាយខ្លួន ប្អូនខ្លួន បានយកលុយសងជម្ងឺចិត្តបានចំនួនប្រហែល ៣០០.០០០រ០០ ឱ្យទៅម្តាយ ៥ល ដែរ ។

-ឈ្មោះ អ ៥ល ជាជនរងគ្រោះឆ្លើយថា មុនពេលកើតហេតុឈ្មោះ ឈ ឧ បានស្តីដណ្តឹងខ្លួនធ្វើជាប្រពន្ធម្តាយខ្លួនយល់ព្រមដែរ កន្លងមកខ្លួនមិនដែលស្គាល់ឈ្មោះ ស ស ហៅ ម នេះទេ ឃើញគាត់មកផ្ទះបងថ្លៃខ្លួនចំនួន ០៣ ដង គឺនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ ស្រាប់តែឃើញ ស ស ទៅដល់ម្តាយខ្លួន ពេលនោះម្តាយខ្លួនមិននៅគឺគាត់ទៅផ្សារវាលវេញ ខ្លួននៅតែពីរនាក់ក្មួយ តែឃើញគាត់នៅទីនោះមានគ្នា ០២នាក់ និង មានស្រាចំនួន ០៣លីត្រយកមកជាមួយផង ពេលមកដល់ផ្ទះគាត់សួររកបងថ្លៃ និង ម្តាយខ្លួន ខ្លួនប្រាប់គាត់ទាំង ០២នាក់នេះ គាត់មិននៅផ្ទះទេគាត់ក៏អង្គុយនៅរានហាលខាងមុខផ្ទះ ខ្លួនក៏បានរៀបចំទៅមើលឡធ្យូង គាត់ក៏សួរនាំខ្លួន ខ្លួនក៏ប្រាប់ថា ទៅឡ ឱ្យគាត់អង្គុយលេងនៅផ្ទះជាមួយក្មួយខ្លួនទៅ ពេលខ្លួនដល់ឡ ស្រាប់តែឃើញឈ្មោះ ស ទៅឡដែរ ក៏បានចាប់ដៃខ្លួន ខ្លួនសួរធ្វើអ្វីហ្នឹង គេក៏ផ្តួលខ្លួនទៅដីរួចស្រាតខោវែង និង ខោខ្លី ដល់ត្រឹមជង្គង់មិនបានស្រាតចេញផុតពីជើង មិនបានថើប ឬស្ទាបដោះអ្វីទេ គាត់យកដៃគាត់ម្ខាងចាប់ដៃខ្លួន និង ដៃម្ខាងទៀតវាស្រាតខោ តែស្រាតមិនបានខ្លួនខិតខំរើបំរះស្រែកឱ្យគេជួយ និង ឱ្យគាត់លែង តែគាត់ស្រាតខោគាត់ទៅវិញ ក៏បានទ្រោបពីលើខ្លួន ហើយមានរបស់អ្វីហាក់ដូចជាចូលក្នុងទ្វារមាសរបស់ខ្លួន ខ្លួនមានការឈឺចាប់ ស្រាប់តែគាត់មានចេញទឹកកាមប្រឡាក់ខោរបស់ខ្លួន ខ្លួនក៏ស្លៀកខោឡើងវិញ គាត់ក៏នាំក្មួយខ្លួនមកផ្ទះ ពេលមកដល់ផ្ទះឈ្មោះ ស គាត់អង្គុយលេងជាមួយពូម្នាក់ទៀត ដែលមកជាមួយគាត់ពេលម្តាយខ្លួនមកក៏បានប្រាប់គាត់ គាត់ក៏នាំខ្លួនទៅប្តឹងដោយឆ្លងកាត់ព្រែក គាត់ក៏នាំទៅសាលាសង្កាត់សំរ៉ុង នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០១ ម្តាយខ្លួននាំខ្លួនមកពេទ្យចំការចេកពិនិត្យមើល ។ កន្លងមកខ្លួនបានរៀបការជាមួយគូដណ្តឹងខ្លួនហើយ ។ ឯលទ្ធភាពទារសំណង គឺខ្លួនទុកលទ្ធភាពឱ្យម្តាយខ្លួនជាអ្នកទារទៅចុះ ។

-ឈ្មោះ គ ៣ ជាដើមបណ្តឹងបានឆ្លើយថា ឈ្មោះ ៥ល ត្រូវជាកូនស្រីពៅរបស់ខ្លួន មានមុខរបរធ្វើចំការផង និង ដុតធ្យូងផង មុនពេលកើតហេតុ កូនខ្លួនត្រូវបានគេស្តីដណ្តឹងរួចហើយ ។ ឈ្មោះ ស ស បានរាប់អានជាមួយកូនប្រសារខ្លួនឈ្មោះ ម ហើយឃើញគាត់ឧស្សាហ៍ទៅលេងកូនប្រសារខ្លួនចំនួន ០៣ដងដែរ នៅថ្ងៃកើតហេតុខ្លួនមិនបានដឹងពីសកម្មភាពរបស់គាត់ធ្វើអ្វីមកលើកូនខ្លួនទេ ព្រោះខ្លួនទៅផ្សារវាលវេញ ពេលត្រឡប់មកវិញ ស្រាប់តែឃើញកូនទទឹកជោគ និង យំផង ហើយវានិយាយប្រាប់ខ្លួនថា ឈ្មោះ ស ស បានចាប់រំលោភវានៅក្បែរឡធ្យូង ព្ធដូច្នេះខ្លួនក៏បាននាំកូនទៅប្តឹងលោក ណ ន ដែលជាអនុប្រធានភូមិ បានជួបគាត់ គាត់នាំទៅសាលាសង្កាត់សំរ៉ុង ជួបចៅសង្កាត់រងទី១ ក្រោយពីធ្វើកំណត់ហេតុនៅសង្កាត់ និង នៅនគរបាលខណ្ឌរួចហើយ លុះព្រឹកឡើងខ្លួនក៏នាំកូនទៅមន្ទីរពេទ្យចំការចេកក្រុងដើម្បីពិនិត្យ គេសុំឱ្យនៅសំរាកព្យាបាលនៅពេទ្យ តែខ្លួនគ្មាននរណានៅផ្ទះ ក៏នាំកូនត្រឡប់មកផ្ទះវិញពេលដល់ផ្ទះសមត្ថកិច្ចនគរបាលទៅដល់ផ្ទះខ្លួនដែរ ខ្លួន និង កូន ក៏នាំសមត្ថកិច្ចទៅពិនិត្យកន្លែងកើតហេតុក្នុងពេលនោះដែរឃើញម្តាយឈ្មោះ ស ស និង សាមីខ្លួន និង បងប្អូនមួយចំនួនទៀតទៅនិយាយ ដោយសុំផ្សំផ្គុំកូនគាត់ជាមួយកូនស្រីខ្លួន ប៉ុន្តែខ្លួនមិនយល់ព្រមជាមួយ ដោយខ្លួនបានបញ្ជាក់ថា កូនខ្លួនបានភ្ជាប់ពាក្យសំដីជាមួយឈ្មោះ ឈ ឧ រួចហើយ ដូច្នេះគេសុំបង់ជម្ងឺចិត្ត ខ្លួនទារ ២.០០០.០០០រ០០ ស ស ថា តាមលទ្ធភាពចំនួន ៥០០.០០០រ០០ ខ្លួនទារ ៨០០.០០០រ០០ តែម្តាយ ស ស ថា បើ ៨០០.០០០រ០០ គាត់ពុំមានលទ្ធភាពទេ ចាប់តាំងពីពេលនោះមកឈ្មោះ ស

ស រត់គេចខ្លួនរហូតមក ។ ប៉ុន្តែកន្លងមកក្រុមគ្រួសាររបស់ ស ស បានផ្តល់ប្រាក់ចំនួន ៣០០.០០០រុ០០ដែរ ខ្ញុំក៏មិនចង់យកទោសពៃរ៍លើឈ្មោះ ស ស ទៀតទេ ស្រេចតែលើច្បាប់ចុះ តែខ្ញុំសុំឱ្យគាត់ដោះស្រាយបន្ថែមទៀត សរុបទាំងមុន និង ក្រោយចំនួន ៥០០.០០០រុ០០ ហើយកូនស្រីខ្ញុំសព្វថ្ងៃវាមានប្តី និង មានកូនមួយទៀតផង ។

-ឈ្មោះ អ ស ជាសាក្សីបានឆ្លើយថា ខ្ញុំត្រូវជាចៅរបស់ឈ្មោះ គ ៧ ឯឈ្មោះ ផល ត្រូវម្តាយមីងខ្ញុំ ខ្ញុំនៅសង្កាត់ជើងពោ ក៏បានមកលេងផ្ទះយាយខ្ញុំឯភូមិអូរត្រជាក់ចិត្ត បានប្រហែល ១០ថ្ងៃ នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ យាយខ្ញុំទៅផ្សារ ខ្ញុំនៅជាមួយមីងនៅផ្ទះដល់ពេលរសៀល ស្រាប់តែឃើញមនុស្សប្រុស ០២នាក់មកដល់ផ្ទះយាយ និង មីងខ្ញុំ ដោយមានស្រាមួយថង់ទៀតផង បានសួររកអ៊ំប្រុសខ្ញុំ ខ្ញុំថា គាត់មិននៅផ្ទះទេ គាត់ក៏អង្គុយនៅទីនោះ បន្ទាប់មកមីងខ្ញុំក៏ធ្វើដំណើរទៅមើលឡធ្យូង ក៏ឃើញពូម្នាក់ធ្វើដំណើរទៅតាមមីងខ្ញុំ ខ្ញុំក៏បានដើរតាមក្រោយមីងខ្ញុំដែរ ពេលខ្ញុំដើរជិតដល់ឡធ្យូងក៏ឃើញពូនោះចាប់មីងខ្ញុំ ខ្ញុំក៏បានស្រែកឱ្យគេជួយ ឯខ្ញុំមិនហ៊ានជួយក៏រត់រកមនុស្សចាស់ៗនៅក្បែរ តែមិនជួបក៏ត្រឡប់មកវិញ ពុំឮសម្លេងមីងខ្ញុំស្រែកទៀតទេឃើញមីងខ្ញុំអង្គុយឯពូនោះគាត់ឈរ បន្ទាប់មកមីងខ្ញុំក៏ដើរត្រឡប់មកផ្ទះ ខ្ញុំក៏ដើរតាមក្រោយ ហើយពូនោះក៏ដើរមកតាមក្រោយដែរ ។

-ឈ្មោះ ណ ន ជាសាក្សីបានឆ្លើយថា ខ្ញុំជាអនុប្រធានភូមិអូរត្រជាក់ចិត្ត នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ វេលាម៉ោងប្រហែល ០៥ និង ៣០នាទី ខ្ញុំនៅផ្ទះបានឃើញឈ្មោះ អ ផល និង ម្តាយគាត់មកដល់ផ្ទះខ្ញុំ ដោយ អ ផល សំលៀកបំពាក់ទទឹកជោគ ហើយប្រាប់ថា ឈ្មោះ ស ស បានចាប់រំលោភវានៅម្តុំឡដុតធ្យូង ដោយជិតយប់ផង ខ្ញុំមិនបានសួរនាំអ្វីទេ ក៏នាំអ្នកទាំងពីរទៅសាលាសង្កាត់សំរ៉ុង ពេលជួបលោកចៅសង្កាត់រងទី១ រួចហើយខ្ញុំក៏ត្រឡប់មកផ្ទះវិញ ។ លុះព្រឹកឡើងក៏ឃើញប្រធានភូមិនគរបាលប៉ុស្តិ៍សង្កាត់សំរ៉ុង និង នគរបាលខណ្ឌព្រៃនប់បានចុះទៅដល់មណ្ឌលអូរត្រជាក់ចិត្ត ទៅដល់កន្លែងកើតហេតុ ដោយជនរងគ្រោះនាំទៅជាមួយផង ។ ឈ្មោះ អ ផល នេះត្រូវបានរៀបការជាមួយគូដណ្តឹងរបស់គេប្រហែលជាមួយខែ ក្រោយពេលដែលឈ្មោះ ស ស ថាបានរំលោភនោះ ។

-តាមការអានចម្លើយរបស់ឈ្មោះ ម អ និង ឈ្មោះ ខ សផ ជានគរបាលឆ្លើយប្រហែលគ្នាថានៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ វេលាម៉ោង ០៤ ទៅ ០៥ល្ងាច បានឃើញឈ្មោះ អ ផល និង ម្តាយព្រមទាំងអនុប្រធានភូមិបានមកប្តឹងថា ឈ្មោះ ស ស ចាប់រំលោភនាង ផល រហូតដល់បានសំរេច ហើយក៏ជំរុញឱ្យជនរងគ្រោះទៅមន្ទីរពេទ្យ ដើម្បីពិនិត្យលើការរំលោភមែន ឬ មិនមែន ។ ហើយជនរងគ្រោះបានរាយការណ៍ប្រាប់ទៀតថា ឈ្មោះ ស ស បានសំរាតខោជើងវែង និង ខោខ្លីត្រឹមតែជង្គង់ទេ រួចរំលោភរហូតដល់ទីជម្រៅ និង ចេញទឹកកាមទៀតផង ។

-បានឃើញលទ្ធផលកោសល្យវិច្ច័យរបស់មន្ទីរសុខាភិបាលក្រុងព្រះសីហនុ លេខ ១៧ ម.ស.សនរច ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ធ្វើការពិនិត្យឈ្មោះ អ ផល ដែលមានខ្លឹមសារដូចខាងក្រោម :

**១-ការពិនិត្យលើរាងកាយ**

-ពុំឃើញមានស្នាកស្នាមអ្វីឡើយ

**២-ការពិនិត្យលើប្រដាប់បន្តពូជ**

-នៅលើក្រដាសព្រហ្មចារីយ៍ពុំឃើញមានស្នាមដាច់រហែក និង ជាំឡើយ

-ក្បាលរហូរឈាមគ្មាន

-មានស្នាមក្រហមប៉ុនចុងកន្ទុយធ្មួបនៅលើបបូរតូច

**៣-សំណើអមត្ថីអិក**

-ទឹកកាម អវិជ្ជមាន

**<u>សេចក្តីសន្និដ្ឋាន</u>** : ពុំមានសញ្ញាបញ្ជាក់គ្រប់គ្រាន់ ដើម្បីធ្វើការសន្និដ្ឋាន ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ **គ ស** ហៅ **គ ម** ពីបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅសង្កាត់សំរ៉ុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ ប៉ុន្តែបើតាមចម្លើយជនល្មើស សាក្សីព្រមទាំងភស្តុតាង ពិសេសលិខិតកោសល្យវិច្ច័យរបស់ពេទ្យឃើញថា គ្មានស្នាកស្នាមអ្វីគួរឱ្យកត់សំគាល់នោះឡើយ ទោះបីគ្មានស្នាកស្នាម ឬ ភស្តុតាងអ្វីក៏ដោយ ក៏តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដដែល ហេតុនេះសុំលោកចៅក្រមជំនុំជំរះវិនិច្ឆ័យទៅតាមច្បាប់ដោយអនុគ្រោះ ។

-ជនជាប់ចោទបានឆ្លើយសំដីចុងក្រោយបង្អស់ថា ខ្លួនគ្មានបានរំលោភសេពសន្ថវៈឱ្យបានស៊ីជម្រៅនោះទេ គឺខ្លួនបានពោបពីលើនាងមែន តែមិនបានយកលិង្គដាក់ចូលក្នុងយោនីនោះឡើយ ព្រោះខ្លួនមិនបានស្រាតខោខ្លួន និងស្រាតខោនាង **ផល** ទេ ក៏ចេញទឹកកាមប្រឡាក់ខោខ្លួនប៉ុណ្ណោះ ហេតុនេះសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផងព្រោះកន្លងមកខ្លួន និង នាង **ផល** ពិតជាស្រឡាញ់គ្នាមែន ក្រោយគេប្តឹងខ្លួនឈ្មោះនាង **ផល** បានរៀបការជាមួយប្រុសថ្មីទៀត ហើយសព្វថ្ងៃនេះមានទាំងកូនថែមទៀតផង ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹង

-ក្រោយពីបានស្ដាប់ចម្លើយ និង ការអានចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានឃើញសាលក្រមកំបាំងមុខលេខ ៤៨ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ របស់តុលាការក្រុងព្រះសីហនុ ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការក្រុងព្រះសីហនុ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-តាមការអះអាងរបស់ជនជាប់ចោទថា ខ្លួនមិនបានរំលោភសេពសន្ថវៈ ដោយយកប្រដាប់ភេទរបស់ខ្លួនដាក់បញ្ចូលទៅក្នុងប្រដាប់ភេទរបស់ឈ្មោះ **ផល** នោះទេ គ្រាន់តែពោបពីលើខ្លួនប្រាណគេក៏ចេញទឹកកាមតែម្ដង ព្រមទាំងប្រឡាក់ខោខ្លីផងដែរ ។ តែទោះបីមិនបានបញ្ចូលលិង្គទៅក្នុងយោនីក៏ដោយ ក៏លិង្គរបស់ខ្លួនទៅប៉ះ និង យោនីរបស់ស្ត្រីដែរ ធ្វើឱ្យខ្លួនរំភើបខ្លាំងពេកក៏ចេញទឹកកាមនោះទៅ បញ្ហានេះក៏ចាត់ទុកជាអំពើមួយដែលបានប៉ះពាល់ដល់កេរ្តិ៍ខ្មាស់របស់ស្ត្រីភេទដែរ ហេតុដូច្នេះក្នុងច្បាប់ក៏មានចែងផងដែរ គឺអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ ។

-តាមចម្លើយរបស់ជនរងគ្រោះថា ឈ្មោះ **ស ស** បានចាប់ខ្លួនរំលោភសេពសន្ថវៈ គឺបានស្រាតខោវែង និងខោខ្លីដល់ត្រឹមជង្គង់ ហើយរំលោភតែម្ដង ការស្រាតខោវែង និង ខោខ្លីដល់ត្រឹមជង្គង់ គឺមិនអាចរំលោភបានឡើយព្រោះថា ខោមានលក្ខណៈតឹងមិនអាចហែកជើងឱ្យមានចន្លោះធំក្នុងការរំលោភបានទេ ។ ការឆ្លើយនេះ គឺមិនសមស្របទាល់តែសោះ ហើយចេះតែឆ្លើយដើម្បីទម្លាក់កំហុសទៅលើជនជាប់ចោទតែប៉ុណ្ណោះ ។

-ផ្អែកតាមលិខិតកោសល្យវិច្ច័យរបស់មន្ទីរពេទ្យបានបញ្ជាក់ទៅលើប្រដាប់បន្តពូជ គឺនៅលើក្រដាសព្រហ្មចារីយ៍ពុំមានស្នាមដាច់រហែក និង ដាំឡើយ លិខិតនេះមានមូលដ្ឋានគួរឱ្យតុលាការយកជាការបាន ។

-បណ្តឹងទាមទារសំណងជម្ងឺចិត្តរបស់ដើមបណ្តឹងមានលក្ខណៈសមស្របតាមច្បាប់ គប្បីតុលាការពិនិត្យពិចារណាដល់ស្ថានភាពរបស់ជនជាប់ចោទផងដែរ ។

-សាលក្រមកំបាំងមុខលេខ ៤៨ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១ របស់តុលាការក្រុងព្រះសីហនុ ដែលបានសំរេចកំបាំងមុខជនជាប់ចោទនោះ គឺមានលក្ខណៈសមស្របតាមច្បាប់ ប៉ុន្តែគប្បីកែប្រែលើចំណុចជាច្រើនដែលទាក់ទងនឹងបញ្ហារឿងនេះ ។

-បណ្តឹងសុំឱ្យតុលាការជំនុំជំរះនៅចំពោះមុខជនជាប់ចោទ គឺមានលក្ខណៈសមស្របតាមច្បាប់ គប្បីតុលាការចាត់ការតាមនីតិវិធីតទៅទៀត ព្រោះជនជាប់ចោទ ក្រោយពេលចាប់ខ្លួនបានក៏តតែប្តឹងទាស់នឹងសាលក្រមកំបាំងមុខនេះដែរ ការប្តឹងទាស់នេះ គឺធ្វើអំឡុងពេលត្រឹមត្រូវ ។

-ជនជាប់ចោទ និង ជនរងគ្រោះ កន្លងមកពិតជាមានការទំនាក់ទំនងគ្នាមែន តែដោយជនរងគ្រោះត្រូវបានភ្ជាប់ពាក្យជាមួយប្រុសផ្សេងទៀត ទើបជនជាប់ចោទហ៊ានប្រព្រឹត្តអំពើយ៉ាងដូច្នេះ ។

-ជនរងគ្រោះមិនមានលក្ខណៈអ្វីឱ្យគ្រោះថ្នាក់ ឬ ប៉ះពាល់ដល់ប្រដាប់ភេទអ្វីដែរ គ្រាន់តែប៉ះពារខាងក្រៅ ឬ ខោតែប៉ុណ្ណោះ គប្បីកែប្រែពីបទរំលោភសេពសន្ថវៈមកអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់វិញ តាមមាត្រា ១០៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-ចម្លើយសាក្សីពុំមានមូលដ្ឋានណាមួយច្បាស់លាស់នោះឡើយ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ស ស** ហៅ **គ ម** ពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស់ ប្រព្រឹត្តនៅសង្កាត់សំរុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**<u>ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ</u>**

**<u>សំរេច</u> :**

**<u>ផ្តន្ទាទោស</u>** :

១-កែប្រែពីបទចោទប្រកាន់របស់តំណាងអយ្យការ ដែលចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ មកអំពើបៀតបៀនកេរ្តិ៍ខ្មាសវិញ តាមមាត្រា ១០៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចាប់តាំងពីពេលនេះតទៅ ។

២-បដិសេធសាលក្រមកំបាំងមុខលេខ ៤៨ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១ របស់តុលាការក្រុងព្រះសីហនុ ចោលជាអសារបង់ ។

៣-ផ្តន្ទាទោសឈ្មោះ **ស ស** ហៅ **គ ម** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ ឆ្នាំ (មួយឆ្នាំ) ក្នុងនោះទោសគុក ០៤ខែ ទោសព្យួរ ០៨ខែ មានរយៈពេលសាកល្បង ០៥ឆ្នាំ គិតពីថ្ងៃផុតកំណត់ទណ្ឌកម្ម ។

ពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស់ ប្រព្រឹត្តនៅភូមិអូរត្រជាក់ចិត្ត សង្កាត់សំរុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤២ មាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤-ឱ្យឈ្មោះ **ស ស** ហៅ **គ ម** សងសំណងជម្ងឺចិត្តជាទឹកប្រាក់ចំនួន ១០០.០០០រ៛០០ (មួយរយពាន់រៀល) ទៀតបន្ថែមពីលើទឹកប្រាក់ចំនួន ៣០០.០០០រ៛០០ ដែលសងមុនទៅជនរងគ្រោះឈ្មោះ **អ ឌល** ដែលមាន

ឈ្មោះ គ ៣ ជាដើមបណ្ដឹង ចាប់តាំងពីសាលក្រមនេះចូលជាស្ថាពរ សំណើលើសពីនេះបដិសេធចោល ។

ក្នុងករណីទណ្ឌិតគ្មានប្រាក់សងធនទណ្ឌទេ ត្រូវដាក់គុកបង្ខំរូបកាយតាមមាត្រា ៧ នៃច្បាប់ ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ ជនរងគ្រោះ ដើមបណ្ដឹងបើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងអំឡុងច្បាប់ ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជំរះ

[redacted]